**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០១៨/១៣/២០០៨ កបធ

# សូមក្រាបបង្គំទូលថ្វាយ
# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

**កម្មវត្ថុ** : សេចក្តីទូលថ្វាយមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះពិធីសច្ចាប្រណិធានដោយឡែកក្នុងការចូលកាន់តំណែងរបស់តំណាងរាស្ត្រទើបជាប់ឆ្នោត មកពីគណបក្ស សម រង្ស៊ី និង គណបក្ស សិទ្ធិមនុស្ស

**យោង** : ព្រះរាជសារ ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ២០០៨

ទូលព្រះបង្គំយើងខ្ញុំ ជាប្រធាន និង សមាជិក សមាជិកា ក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារ ដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០៨ ហើយសូមព្រះរាជានុញ្ញាតទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់ព្រះមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់បំផុត ដូចតទៅ :**

**១**-វាក្យខ័ណ្ឌទី១ មាត្រា ៨២ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា " *រដ្ឋសភាបើកសម័យប្រជុំដំបូងហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ* " ។ យោងតាមវាក្យខ័ណ្ឌខាងលើនេះ ព្រះមហាក្សត្រ ទ្រង់កោះហៅបេក្ខជនជាប់ឆ្នោតជាស្ថាពរទាំងអស់ឱ្យចូលរដ្ឋសភាទទួលព្រះរាជសារ តាមពេលវេលាកំណត់ ។

**២**-ឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យសមាជិករដ្ឋសភាធ្វើសច្ចាប្រណិធាននៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រសម្តេចព្រះសង្ឃរាជ និង ទេវតារក្សាស្វេតច្ឆត្រ មិនមែនអនុញ្ញាតឱ្យបេក្ខជនជាប់ឆ្នោតនោះទេ ។

៣-វាក្យខ័ណ្ឌទី៣ មាត្រា ៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា " *អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ* " ។ អង្គព្រះមហាក្សត្រ មិនអាចបុគ្គលណាស្នើតម្រូវឱ្យព្រះអង្គទ្រង់ព្រះតម្រិះតាមចំណង់ចំណូលចិត្តរបស់ខ្លួនបានឡើយ ។

៤-ព្រះមហាក្សត្រ ព្រះអង្គជានិមិត្តរូបនៃការបង្រួបបង្រួមជាតិ ឯកភាពជាតិ ទ្រង់មានតួនាទីដ៏ខ្ពង់ខ្ពស់ ជាអាជ្ញាកណ្តាលក្នុងការធ្វើឱ្យអំណាចសាធារណៈបានប្រព្រឹត្តទៅជាប្រក្រតី ។

កន្លងមក **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបីតា ឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ** ព្រះអង្គទ្រង់បានព្រះរាជានុញ្ញាតឱ្យសមាជិករដ្ឋសភាធ្វើសច្ចាប្រណិធានទាំងអស់គ្នាតែម្តង ឥតមានការបែងចែកឡើយ ។

សូមព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវភក្តីភាពដ៏ស្មោះ និងការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំ យើងខ្ញុំ ។

ក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**